ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៦៣/០៩-ក្លូប័ល អាប៉ារែល**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **ឈើវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **វ៉ែន តៅ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ក្លូប័ល អាប៉ារែល លីមីធីត**

អាសយដ្ឋាន : ភូមិត្រពាំងទូល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៩៥០ ៩៥៤ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក វឿន វណ្ណារ៉ា មន្ត្រីទំនាក់ទំនង

២- លោក សួង ភន ផ្នែកធនធានមនុស្ស

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : **សម្ព័ន្ធសហជីព សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃរោងចក្រ ក្លូបល**

អាសយដ្ឋាន : ផ្ទះលេខ ៦ សេ ផ្លូវ៤៧៦ សង្កាត់ទូលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៩៨៨ ៦២៣ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោកស្រី មាស វណ្ណី មន្ត្រីសម្ព័ន្ធសហជីព ស៊ីខៅខូ

២- លោក អែម សុភ័ក្រ្ត មន្ត្រីសម្ព័ន្ធសហជីព ស៊ីខៅខូ

៣- លោក ខួត សំណាង ប្រធានសហជីព ស៊ីខៅខូ ប្រចាំរោងចក្រ ក្លូបល

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់ថែមម៉ោងក្នុងខែមីនា ឆ្នាំ២០០៩ ជូនលោក ខួត សំណាង ។ ភាគីក្រុមហ៊ុនបានបើកជូនពីថ្ងៃទី០១ ដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ ។

២- កម្មករទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករចាស់ធ្វើការវេនយប់ បានចូលធ្វើការវិញ ព្រោះសព្វថ្ងៃក្រុមហ៊ុនមានយកកម្មករខាងក្រៅមកធ្វើការវេនយប់ ។ ភាគីក្រុមហ៊ុនបានបញ្ជាក់ថា កម្មករនេះជាកម្មករម៉ៅការប្រើប្រាស់ក្នុងរយៈពេលខ្លី ពេលមានការចាំបាច់ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១៧១/០៩ កប/គណ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩។

## សវនាការ និង សេចក្តីសង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលបណ្តឹងរបស់សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន គ្លូប័ល អាប៉ារែល ទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ ជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ដោយបានទទួលលទ្ធផលសះជាលើការទាមទារចំនួន ០៤ ចំណុច និងមិនសះជាចំនួន ០២ ចំណុច ក្នុងចំណោមការទាមទារទាំងអស់ចំនួន ០៦ ចំណុច។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និង ភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ (វេលាម៉ោង ១៤:០០ នាទី រសៀល )។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ។ ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចទាមទារនេះ ដោយផ្អែកលើភស្តុតាង និង ហេតុផលដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ឧត្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់ប្រធានក្រុមហ៊ុន គ្លូប័ល អាប៉ារែល ជូនលោក វឿន វណ្ណារ៉ា សំរាប់សវនាការសំណុំរឿង លេខ ៦៣/០៩ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ ។

២- សារណាសង្ខេបស្តីពីសំណុំរឿងលេខ ៦៣/០៩ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩។

៣- លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខ ១២៩៥/០៧ គ.វ.ក ជំរាបមកលោកប្រធានក្រុមហ៊ុន Jusca Garment (Cam- bodia) Ltd ស្តីពីសំណើរសុំប្តូរនាមករណ៍ក្រុមហ៊ុន Jusca Garment (Cambodia) Ltd ទៅជាក្រុមហ៊ុន Global Apparels Limited ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០០៧ ។

ARBITRATION COUNCIL

៤- លិខិតរបស់ក្រសួងពាណិជ្ជកម្មលេខ ១៨១០ ពណ.នតក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៧ ជំរាបមក លោកប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ក្លូប៉ល អាប៉ារែល ស្តីពីករណីសុំផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន និងតំកល់លក្ខន្តិកៈថ្មី ។

៥- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មរបស់ក្រុមហ៊ុន ក្លូប៉ល អាប៉ារែល លេខ ២៥៦៥ ពណ.បអព ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧ ។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ប្លាស្កា ហ្គាមេន ចុះបញ្ជីការលេខ ០៧០ ក.ប.វ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០០៤ ។

៧- ប័ណ្ណបើកប្រាក់ខែ ខែមីនា របស់លោក កួត សំណាង ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ក្លូបល ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨។

២- តារាងបើកប្រាក់ឈ្នួល ។

៣- សារណាការពារលើសំណុំរឿងលេខ ៦៣/០៩ នៃរោងចក្រ ក្លូប៉ល អាប៉ារែល ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ ។

៤- ប្រជុំការងារស្តីពីការផ្ទេរវេនយប់ទៅវេនថ្ងៃ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ។

៥- លិខិតរបស់ប្រធានក្រុមហ៊ុន ក្លូប៉ល អាប៉ារែល គោរពជូន បុគ្គលិក-កម្មករវេនយប់ដែលមានកិច្ចសន្យាមិនកំណត់ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ក្លូប៉ល អាប៉ារ៉ែល លេខ ១៧១/០៩ កប/កណ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ក្លូប៉ល អាប៉ារ៉ែល ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣០៧ កប/អក/វក/លកអ. ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣០៨ កប/អក/វក/លកអ. ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩។

ARBITRATION COUNCIL

**ការរកឃើញអង្គហេតុ:**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន កូប៉ល អាប៉ារ៉ែល មានទីតាំងស្ថិតនៅភូមិត្រពាំងទួល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល មានជួលកម្មករនិយោជិតសរុបចំនួន ៩១០ នាក់ ដែលជាភាគីចុងចម្លើយ ។
- ភាគីកម្មករនិយោជិតដែលភាគីនៃដើមបណ្តឹងក្នុងរឿងនេះ តំណាងដោយសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ។

**ចំណុចវិវាទទី១: កម្មករនិយោជិតទាមទារប្រាក់ថែមម៉ោងក្នុងខែមីនា ឆ្នាំ២០០៩ ជូនលោក ខួត សំណាង**

- ភាគីនិយោជក និង ភាគីកម្មករនិយោជិត (លោក ខួត សំណាង) បានទទួលស្គាល់ថា ប្រាក់ឈ្នួលខែមីនា និងប្រាក់ថែមម៉ោង ពីថ្ងៃទី០១ ដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ ត្រូវបានបើក និងទទួលរួចហើយ ។
- ភាគីកម្មករនិយោជិតឈ្មោះ ខួត សំណាង ទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថែមម៉ោង ចាប់ពីថ្ងៃទី១៣ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ព្រោះគាត់មានវត្តមាន និងបានបំពេញការងារចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ដែលមួយថ្ងៃធ្វើការថែមម៉ោងចំនួន ០២ ម៉ោង ដែលក្រុមហ៊ុនមិនទាន់បានបើកឱ្យ ។
- ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនបើកឱ្យទេ ព្រោះ លោក ខួត សំណាង មិនបានបំពេញការងារឱ្យក្រុមហ៊ុន។ ភាគីក្រុមហ៊ុនបញ្ជាក់ថា លោក ខួត សំណាង មិនបានធ្វើការឱ្យក្រុមហ៊ុនទេ ហើយតែងតែដើរចោលកន្លែងការងារពីក្រុម៣៧ ក្នុងអាគារ អាប៊ី ទៅអាគារ ប៊ី និងមិនគោរពតាមការចាត់តាំងរបស់ក្រុមហ៊ុនទេ ការដែលគាត់តែងដើរទៅអាគារផ្សេង ដើម្បីជជែកជាមួយកម្មករដ៏ទៃនោះ ប្រហែលជាគាត់ខ្លាចបាត់បង់សមាជិករបស់គាត់ហើយ ។
- ភាគីនិយោជកបានបង្ហាញបន្ថែមទៀតថា ផ្នែកធនធានមនុស្សរបស់ក្រុមហ៊ុនបានធ្វើការអញ្ជើញគាត់មកណែនាំ និងព្រមានលើកទី១ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ ស្តីពីការមិនផ្តល់ការងារបន្ថែមម៉ោងជូនគាត់ធ្វើទេ បើគាត់មិនខិតខំធ្វើការងារ ហើយនៅតែដើរចោលទីតាំងការងារទៀតនោះ។ ដោយឃើញកម្មករឈ្មោះ ខួត សំណាង នេះ នៅតែប្រកាន់ឥរិយាបថដដែល នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ ផ្នែកធនធានមនុស្សរបស់ក្រុមហ៊ុនបានធ្វើការណែនាំគាត់ជាលើកទី២ទៀត ប៉ុន្តែគាត់នៅតែពុំព្រមធ្វើការងារតាមការចាត់តាំងរបស់ក្រុមហ៊ុនទៀត ហេតុដូចនេះ ក្រុមហ៊ុនក៏សម្រេចមិនផ្តល់ការងារបន្ថែម

THE ARBITRATION COUNCIL

ម៉ោងជូនលោក ខួត សំណាង នេះ បន្តទៀតចាប់ពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ មក ។ ចាប់ពីពេលដែលក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតនេះមក ភាគីក្រុមហ៊ុនបានអះអាងមិនទទួលខុសត្រូវក្នុងករណីដែលកម្មករឈ្មោះ ខួត សំណាង មានវត្តមាននៅវេនបន្ថែមម៉ោងទៀតទេ ។

- លោក ខួត សំណាង បានទទួលស្គាល់ថា ពេលខ្លះលោកពិតជាមិនធ្វើការមែន ព្រោះក្រុមហ៊ុនគ្មានការងារឱ្យគាត់ធ្វើ គាត់គ្មានទីតាំងធ្វើការច្បាស់លាស់ ហើយកន្លងមកក្រុមហ៊ុនក៏មិនដែលបានរៀបចំការងារឱ្យគាត់ឱ្យមានលក្ខណៈល្អប្រសើរទេ ចាប់ពីពេលដែលក្រុមហ៊ុនបានផ្លាស់ប្តូរការងារពីវេនយប់ មកវេនថ្ងៃ ។ ហើយមូលហេតុដែលគាត់ដើរពីអាគារ អាប៊ី ទៅអាគារ ប៊ី ព្រោះគាត់ទៅបន្ទប់ទឹក ។
- ភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមានការងារឱ្យគាត់ធ្វើ ហើយបច្ចុប្បន្ននេះ ក្រុមហ៊ុនកំពុងធ្វើការជ្រើសរើសកម្មករនិយោជិតបន្ថែមជាបន្តបន្ទាប់ទៀតផង ។ ប៉ុន្តែចំពោះកម្មករឈ្មោះ ខួត សំណាង កន្លងមក គាត់មិនបានខិតខំបំពេញការងារដែលនិយោជកបានផ្តល់ជូននោះទេ គាត់តែងតែដើរចោលពីកន្លែងការងារ ហើយទៅជជែកជាមួយកម្មករនិយោជិតដទៃទៀត ជួនពេលខ្លះគាត់បានទៅដេកលេងនៅលើតុការងាររបស់កម្មករដទៃទៀតក៏មានដែរ ។
- ភាគីក្រុមហ៊ុនបញ្ជាក់ថា កន្លងមកក្រុមហ៊ុនតែងតែមានការអធ្យាស្រ័យជូនកម្មករ ខួត សំណាង ជានិច្ច ហេតុដូចនេះហើយបានជានៅតែផ្តល់ប្រាក់ឈ្នួលជូនគាត់ ប៉ុន្តែថ្មីៗនេះ ក្រុមហ៊ុនកំពុងពិចារណា ថាតើគួរផ្តល់ប្រាក់ឈ្នួលសម្រាប់ខែឧសភា ឱ្យគាត់ ឬ អត់ព្រោះ គាត់មិនបានធ្វើការឱ្យក្រុមហ៊ុនទេ ។

**ចំណុចវិវាទទី២: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករចាស់ធ្វើការវេនយប់ចូលធ្វើការវិញ**

- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករចាស់ចូលធ្វើការងារវេនយប់វិញ តាមការសន្យារបស់ក្រុមហ៊ុនកន្លងមក ។
- ភាគីនិយោជក បានលើកឡើងថា ថ្មីៗនេះ ក្រុមហ៊ុនពិតជាមានការងារវេនយប់មែន ប៉ុន្តែវាជាការងារដែលមានរយៈពេលខ្លី (ម៉ៅការ) គឺចាប់ពីថ្ងៃទី២៨ ខែមេសា ដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៩។ ដោយសារសង្វាក់ផលិតកម្មមានការយឺតយ៉ាវ ពុំអាចបញ្ជូនទំនិញទៅអតិថិជនទាន់ពេល ហេតុដូចនេះហើយ ទើបក្រុមហ៊ុនបានជួលកម្មករជំនាញរយៈពេលខ្លី មកបំពេញការងារនេះនៅវេនយប់បន្ថែម ព្រោះក្រុមហ៊ុនពុំមានទីកន្លែង (អាគារ) ទំនេរនៅវេនថ្ងៃទេ សម្រាប់ការងារបន្ទាន់នេះ ។
- ភាគីនិយោជកបានលើកឡើងថា ក្រុមហ៊ុននៅតែមានគោលជំហរទទួលយកកម្មករនិយោជិតចាស់ឱ្យមកធ្វើការវេនយប់ដដែល បើក្រុមហ៊ុនចាប់ដំណើរការការងារវេនយប់ឡើងវិញ ។
- ភាគីកម្មករនិយោជិត និងនិយោជកបានទទួលស្គាល់ថា ក្រុមហ៊ុនគ្មានការងារវេនយប់ទៀតទេ មកដល់ថ្ងៃសវនាការនេះ ព្រោះក្រុមហ៊ុនបានបិទការងារវេនយប់ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៩។

- ភាគីកម្មករនិយោជិតទាមទារនេះ សម្រាប់ពេលអនាគត។

## ហេតុផលនៃសេចក្តីសម្រេចៈ

**ចំណុចវិវាទទី១: កម្មករនិយោជិតទាមទារប្រាក់ថែមម៉ោងចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ជូន លោក ខួត សំណាង**

នៅក្នុងសវនាការ ភាគីកម្មករនិយោជិត ខួត សំណាង បានទាមទារឱ្យក្រុមហ៊ុនបើកប្រាក់បន្ថែមម៉ោងរបស់ខ្លួនចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ព្រោះគាត់បាននៅបំពេញការងារបន្ថែមម៉ោងនេះជូនក្រុមហ៊ុន។ ចំណែកឯភាគីនិយោជកពុំព្រមក្នុងកាផ្តល់ជូននោះទេ ដោយលើកសំអាងថា កម្មកររូបនេះ មិនបានបំពេញការងារជូនក្រុមហ៊ុនទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើក្រុមហ៊ុនត្រូវមានកាតព្វកិច្ចផ្តល់ជូនប្រាក់បន្ថែមម៉ោងនេះ ជូនភាគីកម្មករនិយោជិត ខួត សំណាង ដែរ ឬ ទេ ?

ប្រការ ២ ចំណុច ក (១) នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនបានចែងថា *"និយោជិតកម្មករត្រូវគោរពតាមការណែនាំ និងទទួលខុសត្រូវលើភារកិច្ច និងការងារដែលបានប្រគល់ជូន"*។

មាត្រា ៦៩ កថាខ័ណ្ឌ ១ នៃច្បាប់ស្តីពីការងារបានចែងថា *"នៅក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាកម្មករនិយោជិតត្រូវបញ្ចេញគ្រប់សកម្មភាពវិជ្ជាជីវៈរបស់ខ្លួនដល់សហគ្រាស ជាអាទិ៍ កម្មករនិយោជិតត្រូវធ្វើការ ដែលគេជួលឱ្យធ្វើហើយអនុវត្តការងារនោះដោយខ្លួនឯង និងដោយយកចិត្តទុកដាក់"*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត ត្រូវខិតខំបញ្ចេញគ្រប់សកម្មភាពដោយយកចិត្តទុកដាក់ក្នុងការបំរើការងារជូននិយោជក ក្នុងករណីដែលកម្មករនិយោជិតនោះស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលប្រាក់ឈ្នួលពីក្រុមហ៊ុន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៩/០៩-ប្លូម ថេម ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២)*។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ៤៩/០៩-ប្លូម ថេម ដែរ គឺកម្មករនិយោជិតត្រូវខិតខំបំពេញការងាររបស់ខ្លួនឱ្យអស់ពីសមត្ថភាពជូននិយោជក ក្នុងកំឡុងពេលដែលពួកគាត់ស្ថិតនៅក្រោមការគ្រប់គ្រងចាត់ចែង និងទទួលប្រាក់ឈ្នួលរបស់និយោជកនោះ។

យោងតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និងមាត្រា ៦៩ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត ខួត សំណាង ដែលកំពុងបំរើការងារឱ្យនិយោជករបស់ខ្លួន ត្រូវខិតខំបំពេញការងារឱ្យអស់ពីសមត្ថភាព និងត្រូវគោរពតាមការណែនាំ និងទទួលខុសត្រូវលើភារកិច្ចដែលនិយោជកបានផ្តល់ជូន។ តាមរយៈអង្គហេតុ កន្លងមកកម្មករនិយោជិត ឈ្មោះ ខួត សំណាង ពុំបានខិតខំបំពេញការងារនៅក្នុងពេលបន្ថែមម៉ោងដែលនិយោជកបានផ្តល់ជូននោះទេ។ កម្មករនិយោជិតរូបនេះ តែងតែដើរចោលពីកន្លែងការងាររបស់ខ្លួន តួយ៉ាង

ដូចជាដើរចេញពីក្រុម ៣៧ ក្នុងអាគារ អាប៊ី ដែលជាទីកន្លែងការងាររបស់ខ្លួន ឆ្លងទៅអាគារ ប៊ី ពេលខ្លះទៀត ដើរទៅជជែកលេងជាមួយកម្មករនិយោជិតដទៃទៀត ហើយពេលខ្លះគាត់បានទៅដេកលេងនៅលើតុការងាររបស់កម្មករដទៃទៀតក៏មានដែរ កត្តានេះហើយដែលបណ្តាលឱ្យនិយោជកធ្វើការណែនាំគាត់ចំនួន ០២ លើក បន្ទាប់មកក៏សម្រេចមិនផ្តល់ការងារបន្ថែមម៉ោង ជូនគាត់ធ្វើបន្តទៀតចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ហើយកម្មករនិយោជិត ខ្លួត សំណាង ក៏បានទទួលស្គាល់នូវទង្វើទាំងអស់នេះដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បន្ទាប់ពីនិយោជកបានផ្តល់ដំណឹងជូនកម្មករនិយោជិត ខ្លួត សំណាង នេះរួចមក និយោជកពុំមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់បន្ថែមម៉ោងជូនគាត់ទេ ព្រោះគាត់ពុំបានខិតខំបំពេញការងារតាមការចាត់ចែងរបស់ក្រុមហ៊ុនទេ ថ្វីត្បិតតែគាត់មានវត្តមាននៅក្នុងក្រុមហ៊ុនក្នុងពេលបន្ថែមម៉ោងការងារក៏ដោយ ជាពិសេស គឺគាត់មិនបានបំពេញកាតព្វកិច្ចក្នុងនាមជាកម្មករនិយោជិត ដែលផ្ទុយទៅនឹងមាត្រា ៦៩ នៃច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។

ក្នុងករណីដែលភាគីកម្មករនិយោជិតលើកឡើងថា ក្រុមហ៊ុនពុំមានការងារគ្រប់គ្រាន់ និងពុំបានរៀបចំការងារឱ្យមានលក្ខណៈសមរម្យជូនដល់កម្មករនិយោជិត ខ្លួត សំណាង ធ្វើនោះ ភាគីកម្មករនិយោជិតក៏ពុំបានបង្ហាញភស្តុតាងណាជាក់លាក់ជូនដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធ្វើការពិចារណាឡើយ។ ផ្ទុយទៅវិញ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមហ៊ុនពិតជាមានការងារផ្តល់ជូនកម្មករនិយោជិតធ្វើគ្រប់គ្រាន់មែន តួយ៉ាងបច្ចុប្បន្នក្រុមហ៊ុននៅតែបន្តការជ្រើសរើសកម្មករនិយោជិតជាបន្តបន្ទាប់ ដើម្បីបំពេញចង្វាក់ផលិតកម្មរបស់ខ្លួន។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធលើការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់បន្ថែមម៉ោង ចាប់ពីថ្ងៃទី១៣ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០៩ នេះ ។

**ចំណុចវិវាទទី២: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករចាស់ធ្វើការវេនយប់ចូលធ្វើការវិញ**

ភាគីកម្មករនិយោជិតបានទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករចាស់ចូលធ្វើការងារវេនយប់វិញ តាមការសន្យារបស់ក្រុមហ៊ុនកន្លងមក។ ចំណែកឯភាគីនិយោជកបានលើកឡើងថា ថ្មីៗនេះ ក្រុមហ៊ុនពិតជាមានការងារវេនយប់មែន ប៉ុន្តែវាជាការងារដែលមានរយៈពេលខ្លី (ម៉ៅការ) គឺចាប់ពីថ្ងៃទី២៨ ខែមេសា ដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៩ ។ ភាគីកម្មករនិយោជិត និងនិយោជកបានទទួលស្គាល់ថា ក្រុមហ៊ុនពិតជាគ្មានការងារវេនយប់ទៀតទេ មកដល់ថ្ងៃសវនាការនេះ ព្រោះក្រុមហ៊ុនបានបិទការងារវេនយប់នេះ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៩ មកម្លេះ ប៉ុន្តែតាមរយៈអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីក្រុមហ៊ុននៅតែមានគោលជំហរទទួលយកកម្មករនិយោជិតចាស់ឱ្យមកធ្វើការវេនយប់ដដែល បើក្រុមហ៊ុនចាប់ដំណើរការការងារវេនយប់ឡើងវិញ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ភាគីកម្មករនិយោជិតមានការបារម្ភ ហើយធ្វើការទាមនេះសម្រាប់ពេលអនាគត គឺនៅពេលក្រោយ បើក្រុមហ៊ុនមានការងារធ្វើវេនយប់វិញ ក្រុមហ៊ុនត្រូវទទួលកម្មករចាស់នោះឱ្យចូលធ្វើ

ការវិញ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតនេះ គឺសម្រាប់ពេលអនាគត មានន័យថា មិនទាន់មានវិវាទកើតឡើងនៅឡើយទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់យ៉ាងស៊ីសង្វាក់គ្នាថា ចំពោះវិវាទនៅពេលអនាគត ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនពិចារណាលើការទាមទារនេះទេ ដោយហេតុផល ដូចខាងក្រោម ៖

ទាក់ទងនឹងការទាមទារសម្រាប់ពេលអនាគត នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្កើតឡើង ដើម្បីដោះស្រាយជម្លោះការងារ មិនមែនដើម្បីដោះស្រាយបញ្ហាមិនទាន់កើតឡើងនោះទេ"* ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *១០/០៣-បព្រាក់ស៊ីនតិច ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២, លេខ ១៤/០៦-ក្រុមហ៊ុន សេង យ៉ុង ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី២, លេខ ៣៦/០៩-ស៊ីតាដែល ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១* ) ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយក្នុងសំណុំរឿងខាងលើដែរ ពីព្រោះគ្មាននរណាម្នាក់អាចទាយទុកជាមុនពីហេតុការណ៍ ដែលនឹងកើតមានឡើងនៅពេលអនាគតទេ។ ក្នុងករណីដែលកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករចាស់ឱ្យចូលធ្វើការនៅវេនយប់ដែលក្រុមហ៊ុនពុំមានការងារវេនយប់នេះផ្តល់ជូន តើឱ្យក្រុមហ៊ុនទទួលខុសត្រូវ ដោយផ្តល់ការងារជូនពួកគាត់យ៉ាងដូចម្តេច? មានន័យថា ការងារវេនយប់មិនទាន់កើតមានឡើងទេ ហើយកម្មករនិយោជិតក៏មិនបានបង្ហាញភស្តុតាងពិតប្រាកដក្នុងការទាមទាររបស់ខ្លួនដែរ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករចាស់ធ្វើការវេនយប់ចូលធ្វើការវិញ ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេចដូចតទៅនេះ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១:** បដិសេធលើការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់បន្ថែមម៉ោង ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ។

**ចំណុចវិវាទទី២:** បដិសេធពិចារណាការទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករចាស់ធ្វើការវេនយប់ចូលធ្វើការវិញ ។

ARBITRATION COUNCIL

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈិម គីរម្យ**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ម៉ែន ពៅ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លៈ**

ហត្ថលេខា: ------------------------------